**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

**<u>កិច្ចព្រមព្រៀង</u>**

**ស្តីអំពី**
**ការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត**
**រវាង**
**ក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក**
**និង**
**សហជីពនិងតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ឌីន លីង**

នៅថ្ងៃទី១៩ខែកញ្ញាឆ្នាំ២០២៣វេលាម៉ោង១០និង០០នាទីនៅការិយាល័យក្រុមហ៊ុនឌីនលីងហ្គាម៉ិនឯ.ក មានបើកកិច្ចប្រជុំស្តីពីការដាក់ព្យួរកិច្ចសន្យាការងាររបស់កម្មករនៃក្រុមហ៊ុនឌីនលីងហ្គាម៉ិន ឯ.កខាងមុខនេះ៖

**សមាភាពចូលរួមមាន៖**
-តំណាងក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក
-តំណាងសហជីពនិងតំណាងកម្មករ នៃក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក

ជាកិច្ចចាប់ផ្តើមលោកនាយកក្រុមហ៊ុនបានថ្លែងអំណរអរគុណដល់សមាជិកទាំងអស់ដែលមកចូលរួមប្រជុំ។ បន្ទាប់មកតំណាងក្រុមហ៊ុនបានលើកឡើងថា៖ ដោយសារតែសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះក្រុមហ៊ុនឌីនលីងបានប្រឈមមុខនឹងគ្មានតម្រូវការទីផ្សាររបស់អ្នកប្រើប្រាស់ នឹងគ្មានការបញ្ជាទិញ ទើបក្រុមហ៊ុនសំរេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករទាំងអស់។ដែលមានកម្មករព្យួរសរុប៖ ៩៨៤នាក់ (ស្រី៩០៥ នាក់ )

**ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងអស់បានឯកភាពតាមកាលវិភាគនៃការព្យួរកិច្ចសន្យាការងារនិងប្រាក់ឧបត្ថម្ភដូចខាងក្រោម៖**

១-ក្រុមហ៊ុនឌីនលីងនឹងព្យួរកិច្ចសន្យាការងារ គឺគិតពីថ្ងៃទី២៣ខែកញ្ញាឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣០ខែកញ្ញាឆ្នាំ២០២៣ ។

២-ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភចំនួន១៥ដុល្លា(ដប់ប្រាំដុល្លារអាមេរិក)សំរាប់ការព្យួរកិច្ចសន្យាការងារក្នុងខែកញ្ញាឆ្នាំ២០២៣នេះនៅថ្ងៃទី២០ខែកញ្ញាឆ្នាំ២០២៣អោយបានមុនថ្ងៃព្យួរកិច្ចសន្យាការងារ។

ភាគីទាំងអស់ បានអាននូវខ្លឹមសារ និង យល់ពីអត្ថន័យនៃកិច្ចព្រមព្រៀងយ៉ាងច្បាស់ ហើយបានយល់ព្រមស្ម័គ្រចិត្តផ្តិតមេដៃស្តាំលើកិច្ចព្រមព្រៀងនេះ ដោយគ្មានការបង្ខិតបង្ខំពីជនណាឡើយ។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១១និង០០នាទី នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយ៉ាងស្មោះត្រង់និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
រាជធានីភ្នំពេញ.ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

| តំណាងភាគីសហជីពនិងតំណាងកម្មករនិយោជិក | តំណាងភាគីក្រុមហ៊ុន |
|---|---|
| ស្នាមមេដៃស្តាំ | ហត្ថលេខា និងត្រា |
| | DIN LING GARMENT CO., LTD. |